# បទអន្តរាគមន៍
# សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្តីពីការពង្រឹងការអនុវត្តច្បាប់
# ដើម្បីយុត្តិធម៌ជនរងគ្រោះដោយអំពើជួញដូរមនុស្ស
# ២១ ខែ ធ្នូ ឆ្នាំ ២០១៦

— សូមគោរព សម្តេច ក្រឡាហោម ស ខេង នាយករដ្ឋមន្រ្តីស្តីទី ឧបនាយករដ្ឋមន្រ្តី រដ្ឋមន្រ្តីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាទីគោរពដ៏ខ្ពង់ខ្ពស់

— សូមគោរព ឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្រ្តីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាអនុប្រធាន គ ជ ប ជ ប្រធានក្រុមការងារទេសន្តរប្រវេសន៍ ជាទីគោរព

— សូមគោរព ឯកឧត្តម វង សូត រដ្ឋមន្រ្តីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អនុប្រធាន គ ជ ប ជ ប្រធានក្រុមការងារការពារជនរងគ្រោះ ជាទីគោរព

— សូមគោរព ឯកឧត្តម លោកជំទាវ សមាជិក សមាជិកានៃអង្គសិក្ខាទាំងមូលជាទីគោរព

ជាកិច្ចចាប់ផ្តើមតាងនាមអោយ ឯកឧត្តម អង្គ វង្ស វឌ្ឍានា រដ្ឋមន្រ្តីក្រសួងយុត្តិធម៌ និងជាប្រធានក្រុមកិច្ចការយុត្តិធម៌ នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដែលរៀបចំអោយមានសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិដែលផ្តោលទៅលើ ការអនុវត្តច្បាប់ និងការទទួលបានយុត្តិធម៌របស់ជនរងគ្រោះ ដែលចំនុចនេះទាក់ទងយ៉ាងជិតស្និទ្ធជាមួយការងាររបស់ក្រសួងយុត្តិធម៌ និងស្ថាប័នតុលាការ ដែលទាមទារអោយមានការចូលរួមចែករំលែកចំណេះដឹង និងការអនុវត្តជាក់ស្តែង ជាពិសេសគឺការពិភាក្សាយ៉ាងផុសផុលពីស្ថាប័នទាំងពីរដែលអាចចូលរួមជាធាតុចូលដល់លទ្ធផលនៃអង្គសិក្ខាសាលា។

យោងតាមទិន្នន័យដែលទទួលបានពីសាលាជម្រះក្តី រឿងក្តីពាក់ព័ន្ធនឹងបទល្មើសដែលស្ថិតក្រោមច្បាប់ស្តីពីការបង្ក្រាបអំពើ ~~ស្តីពីការបង្ក្រាម~~អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទនៅតែមានចំនួនច្រើននៅឡើយ ។ មកទល់ខែកញ្ញា ឆ្នាំ ២០១៦នេះ

1. សំណុំរឿងដែលស្ថិតក្នុងចំណាត់ការរបស់អយ្យការ មានចំនួន ៤៨សំណុំរឿង បានចាត់ការរួច ២២ សំណុំរឿង មានជនល្មើស ៥១នាក់ ក្នុងនោះបរទេសចំនួន ១ នាក់។

2. សំណុំរឿងដែលស្ថិតក្នុងចំណាត់ការរបស់ចៅក្រមសើបសួរ មាន ៦៤ សំណុំរឿង បានចាត់ការរួច ១១ សំណុំរឿង មានជនត្រូវចោទចំនួន ៩៣ នាក់ បរទេស ០ នាក់ ជនរងគ្រោះចំនួន ៦៧នាក់
3. សំណុំរឿងដែលស្ថិតក្នុងចំណាត់ការរបស់ចៅក្រមជំនុំជម្រះ មាន ៤៨ សំណុំរឿង ចាត់ការរួច ៧ មានជនជាប់ចោទចំនួន ១០០ នាក់ បរទេស ៣ នាក់ និងជនរងគ្រោះ ៩៥ នាក់។

ដំណើរនីតិវិធីក្នុងដោះស្រាយសំណុំរឿងពាក់ព័ន្ធនឹងការជួញដូរមនុស្សគឺមានរយៈពេលជាមធ្យម លើសពី១ឆ្នាំនៅសាលាដំបូងរាជធានីខេត្ត ឬអាចលើសពីនេះក្នុងករណីដែលដំណើរនីតិវិធីមិនប្រព្រឹត្តិដោយរលូន ដោយសារមានបញ្ហាស្មុគស្មាញក្នុងការប្រមូលព័តមាន ភស្តុតាង និងការកំនត់អត្តសញ្ញាណជនល្មើស និងជនរងគ្រោះ។ ក្នុងករណីដែលមានការអូសបន្លាយពេលវេលាយូរក្នុងការដោះស្រាយ ក្រសួងយុត្តិធម៌បានបង្កើតយន្តការទទួលបណ្តឹង និងតាមដាន ដោយក្នុងនោះភាគីអាចដាក់បណ្តឹងមកក្រសួងស្នើសុំអោយមានការជួយជម្រុញដំណើរការនីតិវិធីតុលាការ និងការផ្តន្ទាទោសអោយបានលឿនបំផុតតាមដែលអាចធ្វើបាន។ ធ្វើលិខិតអន្តរាគមន៍ជូនសាលាដំបូងនីមួយអោយពិនិត្យ និងដោះស្រាយ រឿងក្តីដែលពាក់ព័ន្ធនឹងការជួញដូរមនុស្សអោយបានលឿន។ ដូច្នេះអ្នកពាក់ព័ន្ធទាំងឡាយគួរប្រើប្រាស់យន្តការនេះអោយបានច្រើន ហើយកន្លងមកទាក់ទងនឹងសំណុំរឿងក្តីជួញដូរនេះក៏មិនទាន់មានប្រើប្រាស់យន្តការនេះអោយបានទូលំទូលាយនៅឡើយទេ។

ក្នុងការទទួលខុសត្រូវការពារជនរងគ្រោ ក្រសួងយុត្តិធម៌ ទទួលស្គាល់ថា មានឧបសគ្គជាច្រើនក្នុងការជំរុញអោយជនរងគ្រោះចូលរួមក្នុងនីតិវិធីនៃដំណើរការរឿងក្តីជួញដូរ ហើយដើម្បីអោយជនរងគ្រោះបានចូលរួមកាន់តែពេញលេញក្នុងដំណើរការនេះ មានកិច្ចការជាច្រើនត្រូវអនុវត្ត ។ លើសពីនេះ ដើម្បីកែលម្អសមត្ថភាពរបស់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌដើម្បីរកយុត្តិធម៌ជូនជនរងគ្រោះ ក្រសួងយុត្តិធម៌ និងរួមមានក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាផងបានចុះអនុស្សរណៈជាមួយកម្មវិធីអូស្ត្រាលី អាស៊ីដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស(AAPTIP)ស្តីពីគម្រោងសម្របសម្រួលសាក្សីជនរងគ្រោះ ដែលបានចុះនៅថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៥ ដែលមានរយៈពេល២៤ខែ។ ក្នុងរយៈពេល១០ដំបូង អ្នកសម្របសម្រួលសាក្សីជនរងគ្រោះបានជួយសម្របសម្រួលបានចំនួន ៨សំណុំរឿង ដោយក្នុងនោះ គាត់ត្រូវជួយសម្របសម្រួលជាមួយព្រះរាជអាជ្ញាជាប្រចាំ ផ្តល់ព័តមានអំពីដំណើរការនីតិវិធីតុលាការដល់ជនរងគ្រោះជាដើម និងចូលរួមក្នុងនីតិវិធីតុលការជាមួយជនរងគ្រោះ។ គាត់គឺជាអ្នកជួយជនរងគ្រោះតាំងពីពេលចាប់ផ្តើម ដល់ចប់រឿងក្តី។ សូមសំណូមពរដល់ចៅក្រមព្រះរាជអាជ្ញា សូមអោយមានអ្នកសម្របសម្រួលកាន់តែច្រើន ។

ពាក់ព័ន្ធនឹងសំណងរដ្ឋប្បវេណីនៅក្នុងរឿងក្តីពាក់ព័ន្ធនឹង ការជួញដូរមនុស្ស

ការទទួលបានសំណងរបស់ជនរងគ្រោះគឺជាបណ្តឹងរដ្ឋប្បវេណីដែលជាប់ជាមួយបណ្តឹងព្រហ្មទណ្ឌ។ ដើម្បីអាចអោយតុលាការសម្រេចលើសំណងរដ្ឋប្បវេណីសេចក្តីសម្រេចផ្តន្ទាទោសទៅលើពិរុទ្ធជនត្រូវតែចូលជាស្ថាពរលែង

មានបណ្តឹងទាស់ណាមួយប្រឆាំងនឹងសេចក្តីសម្រេចនោះ។ ហេតុដូចនេះដរាបណានៅតែអត្ថិភាពបណ្តឹងទាស់ប្រឆាំងនឹងសេចក្តីសម្រេចនេះ គឺតុលាការពុំអាចពិចារណា ឬសម្រេចលើបណ្តឹងសំណងរដ្ឋប្បវេណីបានឡើយ។ ម្យ៉ាងវិញទៀត ក្នុងករណីដែលមានសេចក្តីសម្រេចស្ថាពរ ដើម្បីទទួលបានសំណងរដ្ឋប្បវេណី គឺជនរងគ្រោះ ឬភាគីដើមបណ្តឹងត្រូវបន្តចូលក្នុងនីតិវិធីអនុវត្ត ដោយគាត់ជាអ្នកដំបូងដែលត្រូវចាប់ផ្តើមនីតិវិធីដោយស្នើសុំអនុវត្តទៅតុលាការអនុវត្ត។

## បញ្ហាប្រឈម

នៅពេលដែលជនល្មើសជាជនបរទេសដែលមានគោលដៅចុងក្រោយនៅបរទេសដែលធ្វើអោយមានការពិបាកក្នុងការផ្តន្ទាទោស ដូចគ្នាចំពោះជនល្មើសដែលជាមេខ្យល់ មិនស្នាក់នៅក្នុងព្រះរាជាណាកម្ពុជា ដែលជនទាំងនេះតែងតែអវត្តមាន ចូលរួមក្នុងនីតិវិធីតុលាការ ដែលនេះជាកត្តានាំអោយមានការអូសបន្លាយនីតិវិធីយូរ។ ករណីទាំងនេះមិនស្ថិតក្នុងវិសាលភាពនៃការអនុវត្តកិច្ចព្រមព្រៀងស្តីពីបត្យាប័ន និងកិច្ចព្រមព្រៀងស្តីពីការបញ្ជូនទណ្ឌិត ដែលក្រសួងបានចុះជាមួយប្រទេសមួយចំនួន។ ដើម្បីដោះស្រាយបញ្ហានេះ ក្រសួងយុត្តិធម៌ត្រូវបង្កើតកិច្ចសហប្រតិបត្តិការអន្តរជាតិផ្សេងមួយទៀតគឺការចុះសន្ធិសញ្ញាស្តីពីជំនួយទៅវិញទៅមកផ្នែកយុត្តិធម៌ក្នុងវិស័យព្រហ្មទណ្ឌ។ បច្ចុប្បន្ននេះសន្ធិសញ្ញានេះត្រូវបានចុះលើកទីមួយគឺជាមួយប្រទេសវៀតណាមកាលពិម្សិលមិញក្នុងដំណើរទស្សនកិច្ចរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជានៅប្រទេសវៀតណាមថ្ងៃទី ២០ ២១។ ក្រៅពីនេះក្រសួងយុត្តិធម៌ក៏កំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញា ស្តីពីជំនួយទៅវិញទៅមកផ្នែកយុត្តិធម៌ក្នុងវិស័យព្រហ្មទណ្ឌនេះជាមួយប្រទេសថៃផងដែរ។

## ទិសដៅ

បន្តរៀបចំនិងជម្រុញសេចក្តីព្រាងច្បាប់ស្តីពីការបង្ក្រាបអំពើរត់ពន្ធមនុស្សបន្តសហការជាមួយគំរោង AAPTIP ក្នុងការរៀបចំកិច្ចប្រជុំសេចក្តីព្រាងច្បាប់ ស្តីពីជំនួយទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌក្នុងរឿងជួញដូរមនុស្ស
បន្តរៀបចំឯកសារមេរៀន សម្រាប់ធ្វើការបង្រៀនដល់គ្រូបង្គោលបច្ចេកទេសពាក់ព័ន្ធនឹងរឿងជួញដូរមនុស្ស
ពិនិត្យការបង្កើតអោយមានប្រកាសរួមរវាងក្រសួងយុត្តិធម៌ និងក្រសួងសង្គមកិច្ចស្តីពីការផ្តល់នីតិសម្បទា និងអំណាចអ្នកអាណាព្យាបាលដល់មណ្ឌលឬអង្គការដែលទទួលគ្រប់គ្រងថែរក្សាជនរងគ្រោះ
ពិនិត្យការចងក្រងសៀវភៅផ្ទៀងផ្ទាត់សម្រាប់អនុវត្តនីតិវិធីក្នុងរឿងក្តីជួញដូរមនុស្សបន្តការពង្រឹងកិច្ចសហការរវាងស្ថាប័នអយ្យការនិងមន្ត្រីនគរបាលយុត្តិធម៌ដើម្បីការងារប្រមូលព័ត៌មាននិងភស្តុតាង។

ខ្ញុំសូមសំណូមពរ ដល់ឯកឧត្តម អស់លោក ចៅក្រម ព្រះរាជអាជ្ញា មេត្តា ចូលរួមចែករំលែកបទពិសោធន៍ និងចំណេះដឹង អំពីការអនុវត្តជាក់ស្តែងក្នុងកម្មវិធីពិភាក្សារបស់យើង ដើម្បីបំពេញបន្ថែមលើកង្វះខាត និងចំនុចខ្វះចន្លោះនានាក្នុងបទបង្ហាញរបស់នាងខ្ញុំដើម្បីជាធាតុចូលធ្វើអោយ  បំពេញការងារបន្តរបស់យើងនៅពេលត្រលប់ទៅវិញកាន់តែមានប្រសិទ្ធិភាព។

សូមគោរពជូនពរសម្តេច